ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
លេខ ១៣៤៤ សជណ

ចូល 29.12.16

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០១៦

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

**សូមគោរពជូន**

**- សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**- ឯកឧត្ដម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**- ឯកឧត្ដម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**កម្មវត្ថុ ៖** អំពីការពង្រឹងការគ្រប់គ្រងប្រមូលពន្ធប្រថាប់ត្រានៅរាជធានីភ្នំពេញ និងបណ្ដាខេត្តទាំង២៤។

**យោង** ៖ - លិខិតលេខ ១៣៤ សជណ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ១០៧០២ សហវ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនសម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី ឯកឧត្ដមទេសរដ្ឋមន្ត្រី មេត្តាជ្រាបថា ដើម្បីពង្រឹងការគ្រប់គ្រងប្រមូលពន្ធប្រថាប់ត្រាប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព អស់សក្ដានុពល និងផ្ដល់សេវាបង់ពន្ធនេះឱ្យកាន់តែមានភាពងាយស្រួល ព្រមទាំងជំរុញលើកទឹកចិត្តដល់ការចុះបញ្ជីដំបូងនៅរដ្ឋបាលសុរិយោដី រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដូចខាងក្រោម ៖

១. អចលនទ្រព្យដែលពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) ដែលបានផ្ទេរសិទ្ធិកាន់កាប់នៅថ្នាក់ឃុំ សង្កាត់ ឬ ក្រុង ស្រុក ខណ្ឌ ដែលមានសារគារផ្ទេរបន្តដៃគ្នាច្រើនដងមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ អនុញ្ញាតឱ្យបង់ពន្ធប្រថាប់ត្រាតែមួយលើកចុងក្រោយ ដោយអនុគ្រោះឱ្យដកចេញនូវមូលដ្ឋានគិតពន្ធប្រថាប់ត្រា ៦០០ ០០០ ០០០ (ប្រាំមួយរយលាន) រៀល (សមមូលប្រមាណ ១៥០ ០០០ ដុល្លារអាមេរិក) សម្រាប់តែអចលនទ្រព្យដែលបានស្នើសុំចុះបញ្ជីដំបូងនៅរដ្ឋបាលសុរិយោដីប៉ុណ្ណោះ។ ការផ្ដល់ការអនុគ្រោះឱ្យដកចេញនូវមូលដ្ឋានគិតពន្ធប្រថាប់ត្រា ៦០០ ០០០ ០០០ (ប្រាំមួយរយលាន) រៀល គឺមានសុពលភាពអនុវត្តសម្រាប់តែអចលនទ្រព្យដែលបានស្នើសុំចុះបញ្ជីដំបូងនៅរដ្ឋបាលសុរិយោដី ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

ដោយឡែក សម្រាប់អចលនទ្រព្យដែលពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) ដែលបានផ្ទេរសិទ្ធិកាន់កាប់បន្តដៃគ្នាជាច្រើនដងមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ ត្រូវបង់ពន្ធប្រថាប់ត្រាមួយដងលើកចុងក្រោយ (ដោយ

មិនអនុញ្ញាតឱ្យដកនូវមូលដ្ឋានគិតពន្ធ ៦០០ ០០០ ០០០ (ប្រាំមួយរយលាន) រៀល ដូចអចលនទ្រព្យដែលបាន ស្នើសុំចុះបញ្ជីឡើយ)។

២. អាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ (ថ្នាក់ឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ) ត្រូវបញ្ឈប់ការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនបានបង់ពន្ធប្រថាប់ត្រាស្របតាមស្មារតីលិខិតលេខ ១៣៤ សជណ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ចំពោះអចលនទ្រព្យដែលបានទៅចុះបញ្ជីដំបូង ហើយត្រូវបានទទួលការអនុគ្រោះពន្ធតាមចំណុច ១ ខាងលើ ទោះបីជាមានប្រាក់ពន្ធស្មើ ០ (សូន្យ) រៀល ក៏ត្រូវអនុវត្តតាមនីតិវិធី និងបែបបទនៅរដ្ឋបាលសារពើពន្ធជាធរមាន ដើម្បីចុះបញ្ជី និងកត់ត្រាទិន្នន័យនូវអចលនទ្រព្យទាំងនោះ។

ការអនុគ្រោះនេះមិនមានអនុភាពប្រតិសកម្មចំពោះប្រាក់ពន្ធដែលបានបង់រួចហើយនោះទេ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសម្តេចក្រឡាហោម ឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ជ. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

បណ្ឌិត **ហ៊ីង ថូរ៉ាក់ស៊ី**

**ចម្លងជូន ៖**

- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *សាលារាជធានី-ខេត្តទាំង២៤*
- *ឯកសារ-កាលប្បវត្តិ*